00698877

**Declassified to Public**
**12 June 2020**

លេខ / No: D412/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស.**
**និង ០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស.**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 05 / 2011
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| | |
|---|---|
| ចំពោះមុខ ៖ | **ចៅក្រម យូ ប៊ុនឡេង** |
| | **ចៅក្រម Siegfried BLUNK** |
| កាលបរិច្ឆេទ ៖ | ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ |
| ភាសា ៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ ៖ | សម្ងាត់ |

# ដីកាសម្រេចស្ដីអំពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេច លើសំណើរបស់មេធាវីការពារក្ដីសុំពិនិត្យមើល

## សំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**មេធាវីការពារក្ដីទទួលអាណត្តិតំណាងផលប្រយោជន៍របស់ជនសង្ស័យមិនបង្ហាញអត្តសញ្ញាណ**
គង់ សំអុន

00698878

០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស., ០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No: D11/2/1

យើង **យូ ប៊ុនឡេង** និង Siegfried BLUNK (**ស៊ីគហ្វ្រីដ ប្លុង**) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការបើកការស៊ើបសួរស្របតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ និងទីបីរបស់សហព្រះរាជអាជ្ញា ដែលក្នុងនោះជនសង្ស័យចំនួនប្រាំរូបដែលមិនបង្ហាញអត្តសញ្ញាណ ត្រូវបានកំណត់អត្តសញ្ញាណដោយសហព្រះរាជអាជ្ញា

បានឃើញវិធាន ២១ វិធាន ២៣ ស្ទួន វិធាន ៥៥ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ("វិធានផ្ទៃក្នុង")

បានឃើញសំណើសុំរបស់មេធាវីការពារក្តីសុំពិនិត្យមើលសំណុំរឿងលេខ ០០៣ និង ០០៤ ("សំណើសុំដើម") ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១

បានឃើញដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ("ដីកាសម្រេច") ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១

## ការរំលឹកឡើងវិញអំពីនីតិវិធី

១. នៅក្នុងសំណើសុំឲ្យមានការពិនិត្យឡើងវិញនេះ មេធាវីការពារក្តីបានលើកឡើងថា៖

i) ពាក្យសុំដែលធ្វើឡើងដោយកញ្ញា សេង ចាន់ធារី និង លោក Robert Hamill ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ ០០៣ និង លេខ ០០៤ បង្កើតបានជាការផ្លាស់ប្តូរកាលៈទេសៈជាក់លាក់[1] ។

---

[1] សំណើសុំឲ្យពិនិត្យឡើងវិញ កថាខណ្ឌ ១១-១៩ ។

ii) សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំនៅក្នុងសំអាងហេតុទាក់ទងនឹងបញ្ហាមួយចំនួនក្នុងដីកាសម្រេច[2] ។

iii) ដីកាសម្រេចបណ្តាលឲ្យមានភាពអយុត្តិធម៌ចំពោះជនសង្ស័យមិនបង្ហាញអត្តសញ្ញាណ[3]។

## សំអាងហេតុនៃសេចក្តីសម្រេច

**<u>ការអះអាងអំពីការផ្លាស់ប្តូរកាលៈទេសៈដែលបណ្តាលឲ្យមានភាពអយុត្តិធម៌ចំពោះជនសង្ស័យមិនបង្ហាញអត្តសញ្ញាណ</u>**

២. សហចៅក្រមស៊ើបអង្កេតធ្វើការរំលឹកឡើងវិញអំពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលត្រូវបានយោងនៅក្នុងសំណើសុំឲ្យមានការពិនិត្យឡើងវិញ[4] ក៏ដូចជាអំពីយុត្តិសាស្ត្រអន្តរជាតិនានាទាក់ទងនឹងអំណាចផ្ទាល់របស់អង្គជំនុំជម្រះ ឬចៅក្រមក្នុងការពិនិត្យឡើងវិញលើសេចក្តីសម្រេចដែលបានធ្វើរួចហើយ ។

៣. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា បញ្ហាដែលចោទឡើងថា តើគួរ ឬពុំគួរធ្វើការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួននោះ គឺជាអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត[5] ហើយ

---

[2] សំណើសុំឲ្យពិនិត្យឡើងវិញ កថាខណ្ឌ ២០-៤៣ ។

[3] សំណើសុំឲ្យពិនិត្យឡើងវិញ កថាខណ្ឌ ៤១-៤៣ ។

[4] 002/19-09-2007-ECCC/OCIJ (PTC03), **C22/I/68** សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ២៥-២៨ ("សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ") ។

[5] *Mucić និងអ្នកផ្សេងទៀត*, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីអំពីការសម្រេចទោស (Judgment on Sentence Appeal) សំណុំរឿងលេខ IT-96-21-A *bis*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៣ កថាខណ្ឌ ៤៩ ។ *Bagosora និងអ្នកផ្សេងទៀត*, (សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បកស្រាយទាក់ទងនឹងការបដិសេធការសុំឲ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចអំពីវិធានការការពារ និងសំណើសុំអំពីការសុំឲ្យប្រកាសអំពីកង្វះយុត្តាធិការ (Decision on Interlocutory Appeal from Refusal to Reconsider Decisions Relating to Protective Measures and

ការពិនិត្យឡើងវិញនេះនឹងត្រូវធ្វើឡើងតែក្នុងករណីពិសេសមួយចំនួនប៉ុណ្ណោះ ដែលក្នុងនោះការផ្លាស់ប្តូរកាលៈទេសៈថ្មីបានបណ្តាលឱ្យមានភាពអយុត្តិធម៌ ឬព្យសនកម្ម[6] ។

៤. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ចំពោះការណ៍ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ សេង ចាន់ធារី និង លោក Robert Hamill មិនទាន់ត្រូវបានដាក់នៅពេលដែលសំណើសុំដើមត្រូវបានដាក់រួចហើយនោះ ការណ៍នេះមិនអាចជាការផ្លាស់ប្តូរពិសេសនៃកាលៈទេសៈ ឬអាចបណ្តាលឱ្យមានភាពអយុត្តិធម៌ចំពោះជនសង្ស័យមិនបង្ហាញអត្តសញ្ញាណឡើយ ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនេះ ត្រូវបានបដិសេធមិនទទួលយកដោយសហចៅក្រមស៊ើបអង្កេតប៉ុន្មានថ្ងៃបន្ទាប់ពីបានដាក់ ដោយអនុលោមតាមវិធាន ២៣ ស្ទួន (២) នៃវិធានផ្ទៃក្នុង ។ ហើយអ្នកដាក់ពាក្យសុំទាំងពីររូបនេះមិនធ្លាប់បានទទួលនូវ "សិទ្ធិចូលមើលសំណុំរឿងដោយសេរី" ដូចដែលមេធាវីការពារក្តីបានលើកឡើងនោះឡើយ[7] ។ ហេតុដូច្នេះ ពួកគេមិនអាច "មានលទ្ធភាពកសាងសំណុំរឿងរបស់ពួកគេប្រឆាំងនឹងជនសង្ស័យមិនបង្ហាញអត្តសញ្ញាណ" ឡើយ[8] ។

---

Application for a Declaration of "Lack of Jurisdiction") សំណុំរឿងលេខ ICTR-98-41-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០០២ កថាខណ្ឌ ១០ ។

[6] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ២៥ ។ សូមមើលផងដែរ *Brima និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ SCSL-2004-16-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ៦៣ ។ *Ntagerura និងអ្នកផ្សេងទៀត*, សេចក្តីសម្រេច, សំណុំរឿងលេខ ICTR-99-46-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៦, កថាខណ្ឌ ៥៥ ។ *Kajelijeli,* សេចក្តីសម្រេច, សំណុំរឿងលេខ ICTR-98-44A-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៥, កថាខណ្ឌ ២០៣ ។ *Nahimana និងអ្នកផ្សេងទៀត*, សេចក្តីសម្រេចស្តីអំពីសំណើសុំឱ្យមានការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥ (Decision on Jean-Bosco Barayagwiza's Request for Reconsideration of Appeals Chamber Decision of 19 January 2005) សំណុំរឿងលេខ ICTR-99-52-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៥, ទំព័រ ២។ *Galić*, សេចក្តីសម្រេចលើសំណើសុំឱ្យមានការពិនិត្យឡើងវិញរបស់មេធាវីការពារក្តី (Decision on Defence's Request for Reconsideration) សំណុំរឿងលេខ IT-98-29-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍., ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ២ ។

[7] សំណើសុំឱ្យពិនិត្យឡើងវិញ កថាខណ្ឌ ១៥ ។

[8] ដូចខាងលើ ។

៥. មេធាវីការពារក្តីថែមទាំងបានធ្វើការសន្មតប៉ាន់ស្មានទាក់ទងនឹងអត្តសញ្ញាណរបស់ជនសង្ស័យមិនបង្ហាញអត្តសញ្ញាណនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ប៉ុន្តែផ្ទុយទៅវិញបែរជាព្យាយាមលើកឡើងថាការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានបណ្តាលឱ្យមានព្យសនកម្មចំពោះជនសង្ស័យទាំងនេះទៅវិញ។ ទោះបីជាយ៉ាងណាក្តី ចំពោះការណ៍ដែលមេធាវីការពារក្តីបានលើកឡើងអំពីជនសង្ស័យដែលខ្លួនពុំបានស្គាល់ផងនោះ ថាបានទទួលរងព្យសនកម្ម គឺជាការអះអាងមួយដែលមានសភាពឥតន័យយ៉ាងជាក់ស្តែង ។

**<u>ការអះអាងអំពីការភ័ន្តច្រឡំរបស់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើសេចក្តីសម្រេច</u>**

៦. មិនមានភាពចាំបាច់ក្នុងការធ្វើការឆ្លើយតបចំពោះទឡ្ហីករណ៍ ដែលលើកឡើងដោយមេធាវីការពារក្តីទាក់ទងនឹងការភ័ន្តច្រឡំ ដែលបានចោទប្រកាន់ថាត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនោះឡើយ ដោយហេតុថាទឡ្ហីករណ៍ទាំងនោះគ្រាន់តែជាការលើកឡើងដដែលៗ ដែលមានរួចហើយនៅក្នុងសំណើសុំដើម ។

**អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេត**

- **សម្រេច** បដិសេធសំណើសុំឱ្យពិនិត្យឡើងវិញនេះ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

យូ ប៊ុនឡេង

**Dr. Siegfried BLUNK**